# ១០~រឿង ឥម្លូវប្រាំពីរសន្ដាន

កាលពីព្រេងនាយមានបុរសប្ដីប្រពន្ធ នាំគ្នាទៅសួរបងប្អូននៅភូមិព្រៃសណ្ដែក ដើរៗទៅប្រទះនឹងបុរសដំឡូងម្នាក់កំពុងតែទឹមគោភ្ជួរស្រែ ។ បុរសប្ដីប្រពន្ធនោះសួរថា "អ្នកអើយអ្នក! ផ្លូវណាកាត់ទៅលើភូមិព្រៃសណ្ដែក ត្បិតខ្ញុំខានមកយូរឆ្នាំហើយ មិនដឹងផ្លូវណាកាត់ទៅអោយត្រង់ ?" ។

បុរសដំឡូងនោះស្រាប់តែខឹងឆ្លើយថា "គោអញ១នឹមនេះសុទ្ធតែកូនក្រោលបង្គោលស្ទឹងអាក្រហម១នេះ ម្ដាយក្មេកគាត់ចែកឯអាស្មែងកន្ទែក ឪអញគាត់អោយអញមិនលួចរបស់អាណាយកមកទឹមទេ" ។

ឯបុរសប្ដីប្រពន្ធដែលសួរផ្លូវនោះឮហើយ និយាយគ្នាថា "អ្នកនេះយើងសួរផ្លូវគាត់ៗនិយាយពីគោហើយស្ដីគំរោះគំរើយអោយយើងផង ណ្ហើយគេហ៍! យើងកុំឱ្យសួរវា យូរនាប់គង់តែនឹងទៅដល់ផ្ទះបងប្អូនមិនខាន" ហើយក៏បណ្ដើរគ្នាហួសទៅ ។ បុរសដំឡូងនោះក៏ខំភ្ជួរស្រែមិនឈប់ដល់ពេលថ្ងៃជិតត្រង់ស្រីដំឡូងជាប្រពន្ធក៏ទូលបាយទៅអោយប្ដីបរិភោគ លុះទៅដល់ដាក់ល្អីបាយក្រោមម្លប់ឈើនៅភ្លឺស្រែ ។ ប្ដីឃើញប្រពន្ធយកបាយមកអោយក៏ឈប់ភ្ជួរស្រែបរិភោគបាយ ទាំងខ្សឹបប្រាប់ប្រពន្ធថា "មានមនុស្សប្ដីប្រពន្ធបណ្ដើរគ្នាមកពីណាចោទប្រកាន់ថា អញលួចគោវា ឯគោ១នឹមនេះ ប្រាកដជាម៉ែឪឯងចែកមក" ។ ប្រពន្ធឃើញប្ដីនិយាយម្ហូបៗនឹកស្មានថា ស្ដីអោយខ្លួន ស្រាប់តែខឹងហើយឆ្លើយតបវិញថា "អញគិតថាប្ដីមកភ្ជួរស្រែទាល់ថ្ងៃត្រង់ខំប្រញាប់ប្រញាល់ទូលបាយមកអោយស៊ី ឥឡូវទៅជាថាឯងមានសហាយ អញមានសហាយនឹងឈ្មោះអាណាគាត់រកមុខអោយឃើញ" ។ ឯប្ដីមិតតែពមបាយអស់មួយកូនល្អីប្រពន្ធថាអ្វីក៏មិនឮផង ។លុះប្ដីបរិភោគរួចប្រពន្ធកន្ត្រាក់យកល្អី ។ ប្ដីសួរថា "ឯងមានការអ្វីឯផ្ទះបានជាប្រញាប់ម្ល៉េះ ?" ។ ប្រពន្ធថា "អញមុខជាប្រាប់ម៉ែឪអញមិនខាន" ហើយកណ្ដៀតល្អីត្រឡប់ទៅដល់ផ្ទះជួបនឹងម្ដាយ និយាយទាំងខឹងមុខក្រហមប្រាប់ម្ដាយថា "កូនប្រសាម៉ែឯងវាល្អហើយ ខ្ញុំទូលបាយទៅអោយស៊ី ដាក់ល្អីស្ទើរតែមិនទាន់ វាស្ដីអោយខ្ញុំថា មានសហាយ" ។

ចំណែកម្ដាយនោះខឹងញ័រឡើងថា "ហាងឯងដូច្នេះទេតើ បានជាមុខក្រហមអញថាកូនថាចៅបានជាចាំផ្ទះអោយវា ឥឡូវវាថាឯងលួចថ្នាំវាយកទៅដូរដូង មេអន្ដរធានឯងក្រោយៗ កុំនិយាយដូច្នេះមិនត្រូវទេ សូម្បីតែថ្នាំ១ផ្ទុកក៏អញមិនលួចយកផង បើទុកជាអញយកមែន ម្ដាយនិងកូនមិនត្រូវហាងឯងពោលអោយអញខ្មាសគេទេ ចាំឪហាងឯងមកអញប្រាប់អោយជេរវាយប្រដៅហាងឯងមិនខាន" ។

លុះយូរបន្ដិច ប្ដីមកពីកាប់បង្គោលធ្វើរបងបង្ការមិនអោយគោក្របីចូលស៊ីសំណាបសំទូង ប្រពន្ធនិយាយប្រាប់ប្ដីថា "កូនស្រីយើងវាយកបាយទៅអោយប្ដី ខ្ញុំចាំផ្ទះអោយវាៗមកវិញវាថាខ្ញុំជាម្ដាយលួចថ្នាំដូរដូងខ្ញុំខឹងណាស់" ។

ប្ដីស្ដាប់មិនឮ ខឹងនឹងប្រពន្ធក៏ជេរថា "មេចោរគ្រហរ!ហាងឯងប្រច័ណ្ឌអញអីម្ល៉េះអញមានស្លៀកពាក់តែងតួដើរលេងចង់ស្រីឯណា អញទៅកាប់ឈើធ្វើបង្គោលរបងទេតើ អញអត់តែម្ដងនេះទេ ក្រោយៗ បើហាងឯងនៅតែស្ដីប្រច័ណ្ឌអញទៀត មុខជាអញផាក់អោយដួលទាំងជំហរមិនខាន" ហាមប្រពន្ធហើយបរិភោគបាយរួចទៅចងសន្ទូចបានត្រីត្រឡប់មកផ្ទះវិញ ។ វេលាថ្ងៃល្ងាច ប្រពន្ធក៏ធ្វើត្រីស្លអាំងអោយប្ដីបរិភោគខ្លះ រំលែកទុកព្រឹកខ្លះ ដើម្បីនឹងធ្វើសំរាប់យកទៅប្រគេនលោកកូនឯវត្ត និង កូនប្រុសម្នាក់អោយនៅរៀនអក្សរជាមួយនិងលោកបងនោះ ។

លុះព្រឹកឡើងម្ដាយនោះដាំបាយដួសដាក់ចានមានម្ហូបពីហ្វេចស្រាប់ ទូលយកទៅដល់កុដិប្រគេនលោកកូន ហើយនិយាយថា "ខ្ញុំព្រះករុណារលឹកលោកកូនណាស់ មួយទៀតប្អូនតូចវារៀនអក្សរគ្រាន់បើទេ ?" ។ លោកកូននោះប្រាប់ថា "អាត្មាសព្វថ្ងៃនេះកំពុងស្រឡាញ់សីលផ្អសណាស់ អាត្មាមិនសឹកទេ" ។ ម្ដាយក៏ហៅកូនតូចដែលនៅបំរើបងនោះថា "អានាង! លាលោកបងទៅផ្ទះនឹងម្ដាយ បានមួយថ្ងៃពីរថ្ងៃសិនត្បិតឪឯង

រលីកណាស់” ។កូនតូចឆ្លើយប្រាប់ម្តាយថា“ត្រីងៀតលោកបងនៅពីរកន្ទុយទុកក្នុងកុដិនេះ ពេលល្ងាចខ្ញុំយកពីរចំរៀកដុតស៊ីបាយ ដែលសល់ពីលោកឆាន់ពេលព្រឹកនោះ” ។

ឯលោកសង្ឃដែលគង់នៅជិតកុដិទាំងប៉ុន្មាន បានឮម្តាយលោក និងកូននិយាយតែដោយខ្លួនមិនទទួលសំរុងគ្នាដូច្នេះ លោកទាំងអស់ទប់ពុំបានក៏សើចទ្រហឹងអឹងអាប់ ។ សិកានោះក៏សំពះលាលោកកូនត្រឡប់មកដល់ផ្ទះវិញ ហើយលុតជង្គង់ជូនបុណ្យប្តីថា “ខ្ញុំជូនបុណ្យអ្នកផង ” ។ ប្តីឆ្លើយថា“អើ អញឃើញបាយសម្លខអាំងព្យួរទុកនៅសង្រែកអញស៊ីអស់ទៅហើយ” ។ ប្រពន្ធក៏មើលមុខប្តីៗមើលមុខប្រពន្ធបំប្រិចភ្នែកម៉ក់ៗ ធ្វើវាហីតែដោយខ្លួន ។ លុះយូរបន្តិចស្រាប់តែប្អូនស្រីបង្កើតខាងប្តីនៅភូមិដទៃឆ្ងាយមកដល់ បានផ្លែពង្រមួយផ្តិល និង ស្លឹកប្រស់ស្វាមួយសំណុំមកផ្ញើបង និយាយសួរថា“បងបានភ្ជួររាស់ដកស្ទូងបានស្រែប៉ុន្មានហើយ ?” ។ បងទាំងប្តីប្រពន្ធឆ្លើយប្រាប់ទៅប្អូនស្រីវិញថា“អើហាង! ល្មមទុកដាក់អោយវាមានប្តីទៅចុះ តែហាងមើលកុំអោយតែចេះលេងបៀ ផឹកស្រា ជក់អាភៀន” ។

ប្អូនស្រីស្តាប់មិនឮទៀត ក៏ប្រាប់ទៅបងទាំងពីរនាក់ថា“ខ្ញុំស្តាយត្រឡាចខ្ញុំមួយទ្រើងណាស់ កំពុងតែផ្លែក្តិបតូចៗ ស្រាប់តែមានមេជ្រូកឈ្មុសគល់ដាច់ងាប់អស់” ។ បងទាំងពីរនាក់ថា“អើហាង! ល្មមទៅផ្ទះក៏ទៅល្ងាចណាស់ហើយក្រែងកូនវាយំរក” ។ ប្អូនស្រីនោះក៏ត្រឡប់មកវិញ ។

ព្រោះអ្នកទាំង ៧ នាក់ គឺបុរស ស្ត្រី ប្តីប្រពន្ធ ម្តាយឪពុក លោកភិក្ខុ កុមារជាប្អូន និងប្អូនស្រីសុទ្ធតែថ្លង់និយាយមិនចុះសំរុងគ្នាបានជារឿងនេះគេហៅថារឿងដំឡង់ ៧ សន្តាន ។

**ស្តាប់មិនឆាន់ជាក់ កុំអាលញាក់ចិញ្ចើម**